# គីមសែត

(១៩៣១-១៩៧៥)

ដោយ

បណ្ឌិតសភាចារ្យ **ឃីជ័ហុកឌី**

កើតនៅរវាងឆ្នាំ ១៩៣១ នៅកម្ពុជាក្រោម ក្នុងខេត្តព្រះត្រពាំង(ត្រាវិញ)[1] ហើយបានបាត់ខ្លួនរវាងឆ្នាំ១៩៧៥ ។

លោកចេះភាសាយួននិងភាសាបារាំងយ៉ាងច្បាស់លាស់។ បានធ្វើជាសាស្ត្រាចារ្យភាសានិងអក្សរសិល្ប៍ខ្មែរនៅសាលាឯកជនដើម្បីចិញ្ចឹមជីវិតជាពិសេសគឺនៅ វិទ្យាល័យ**កម្ពុជបុត្រ** ដោយលោកជាមិត្តស្រុកជាមួយនឹងលោកអៀងសារី[2]ដែលបង្រៀននៅអនុវិទ្យាល័យនេះដែរហើយនិងជាមិត្តលោកសឺនសេន[3]ដែលមានស្រុកកំណើតជាមួយគ្នា។ លោកបានសរសេរ

[1] ពត៌មាននេះបានពីលោកសាស្ត្រាចារ្យវេជ្ជបណ្ឌិត ថាច់ត្វាន់។ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសមាចិត្តល្អលោកដែលបានឆ្លើយតបយ៉ាងឆាប់រហ័សនឹងសំណួរខ្ញុំ។

[2] អៀងសារី (១៩២៩-២០១៣) នាមដើម "គីមត្រាង" កើតនៅត្រាវិញ ជាស្រុកកំណើតលោកគីមសែតដែរ។

[3] សឺនសេន (១៩៣០-១៩៩៧)ជាចាងហ្វាងរងនៅវិទ្យាស្ថានគរុកោសល្យជំនាន់នោះដែលមានសាស្ត្រាចារ្យកេងវ៉ាន់សាក់ជាចាងហ្វាង។

កាសែតខ្មែរខ្លះៗដែរដើម្បីដោះស្រាយជីវភាពនៅកម្ពុជា ដូចជាកាសែតមាតុភូមិជាដើមដោយមានចាងហ្វាងការផ្សាយនាមសឹងកៀកថ[4] ជាខ្មែរកម្ពុជាក្រោមដូចគ្នា។ លោកបានបកប្រែរឿងចិនតាមរយៈភាសាយួនព្រោះលោកចេះភាសានេះច្បាស់លាស់គឺបកប្រែចេញពីអត្ថបទអក្សរសិល្ប៍ចិន-យួន (Littérature sino-vietnamienne) ចុះផ្សាយក្នុងទំព័រទី៣នៃកាសែតនេះ។ បន្ទាប់ពីរដ្ឋាភិបាលសង្គមរាស្ត្រនិយមនៅឆ្នាំ១៩៦៧បានបិទកាសែតឯកជនទាំងអស់ទុកតែសារពត៌មានរដ្ឋជាភាសាខ្មែរដូចជាកាសែតអ្នកជាតិនិយម, ទស្សនាវដ្ដីផ្សេងៗ ជាដើម។[5] កាសែត មាតុភូមិ ដោយមិនអាចចេញផ្សាយបានក៏ប្រែវិជ្ជាជីវៈទៅបោះពុម្ពផ្សាយ ការបកប្រែរឿងប្រលោមលោកពីភាសាចិន-យួនមកជាភាសាខ្មែរដោយលោកគីមសែតនិងសហការី គឺបានផ្សាយ ជាវគ្គៗ ឬជាខ្សែ

---

[4] កើតនៅថ្ងៃទី៥ឧសភា គ.ស. ១៩២០ក្នុងខេត្តត្រាវិញ "កម្ពុជាក្រោម" ជាអ្នកកាសែតនិងជាអ្នកនិពន្ធដែលមានឈ្មោះល្បីមួយរូបដែរ។ លោកបានសរសេរ ប្រលោមលោក រឿង "ព្រះខ័នរាជ"នៅឆ្នាំ១៩៥៥, រឿង"បក្សចម្ប៉ាខ្មៅ" នៅឆ្នាំ១៩៥៥។លោកជាស្ថាបនិកកាសែត "មាតុភូមិ" នាទសវត្សរ៍១៩៦០។ លោកជាសមាជិកគណបក្សប្រជាធិបតេយ្យ ហើយបានជាប់ឆ្នោតជាតំណាងរាស្ត្រនៅឆ្នាំ១៩៥១ក្នុងមណ្ឌល"តាំងក្រាំង"នៅក្នុងខេត្តកំពង់ចាម។ សូមអានបន្ថែមពីជីវប្រវត្តិលោក សឹងកៀកថ ក្នុងសៀវភៅជាភាសាអង្គ្លេស CORFIELD Justin & SUMMERS Laura, *Historical Dictionary of Cambodia*, Lanham, Maryland, and Oxford, The Scarecrow Press, 2003, p. 394 ។ សូមអរគុណចំពោះបណ្ឌិតសភាចារ្យ រស់ចន្ទ្រាបុត្រដែលបានផ្ដល់ពត៌មានបន្ថែមលើ អ្នកនិពន្ធគីមសែតនេះ។

[5] សូមអានបន្ថែម សៀវភៅ ជាភាសាបារាំងដោយឃីងហុកឌី, *Ecrivains et expressions littéraires du Cambodge au XXème siècle*, Paris, L'Harmattan, 1993 : « Presse », p. 4-6.

តូចៗចេញលក់ជារៀងរាល់ថ្ងៃដែលមហាជនអានជក់ចាប់ចិត្ត ចាប់អារម្មណ៍នៅសម័យនោះ។ អក្សរសិល្ប៍ប្រភេទនេះមាន ប្រជាប្រិយភាពយ៉ាងខ្លាំងក្លាលើជនានុជននារយៈពេលនោះ ដោយខ្វះកាសែតអាន។

នាឆ្នាំ១៩៦៩ រដ្ឋាភិបាលបានអនុញ្ញាតឲ្យសារពត៌មានឯកជនចេញផ្សាយឡើងវិញ។ ពេលនោះកាសែតនានាក៏ចាប់ផ្តើមមានជីវិតម្តងទៀត។

លោកគីមសែតមានទំនោរនយោបាយជឿនលឿននិយម ឬ ឆ្វេងនិយម (tendance progressiste ou gauchiste)។[6] លោកមិនដែលបានចូលធ្វើការជាមន្ត្រីរាជការទេ ហើយលោកក៏គ្មានសញ្ញាប័ត្រអ្វីខ្ពង់ខ្ពស់ដែរព្រោះលោកបានរៀននៅកម្ពុជាក្រោមនិងនៅកម្ពុជាបានត្រឹមតែក្នុងវិទ្យាល័យប៉ុណ្ណោះ។

តាមប្រភពខ្វះ ថាលោក ជាមិត្តភ័ក្តិជិតស្និទ្ធនឹងអ្នកនិពន្ធល្បីមួយរូបទៀតគឺលោកជូថានី ដែលជាអ្នកបង្កើតកាសែត "**កោះសន្តិភាព**" នៅឆ្នាំ១៩៦៧សហការជាមួយលោកសុទ្ធប៉ូ

---

[6] យោងតាមសារអេឡេត្រូនិច លោកសាស្រាចារ្យវេជ្ជបណ្ឌិត ថាច់ត្វាន់ និង លោកបណ្ឌិតសភាចារ្យ រស់ចន្ត្រាបុត្រ។

លីន។ តែក្រោយមកលោកសុទ្ធប៉ូលីន បានបង្កើតកាសែតថ្មីរបស់លោកផ្ទាល់នៅវាងឆ្នាំ១៩៦៩ ឈ្មោះ"**ឯករាជ្យ**"។[7]

លោកជាអ្នកនិពន្ធប្រលោមលោកនិងសៀវភៅសិក្សាជាច្រើន។

ប្រលោមលោកសំខាន់ៗមាន៖

១-ស្រមោលមហាចោរ, ១៩៥១, ៧៣ទំព័រ។

២-ស្នេហាកាំភ្លើងនៅក្រោយភ្លៀងធ្លាក់, ១៩៥២, ៩៦ទំព័រ។

៣-ជើងមេឃថ្មី, ១៩៥៥, ៦៨ទំព័រ។

៤-នារីរាត្រី, ១៩៥៥, ៦៦ទំព័រ។

៥-ស្នេហាចិត្តមួយ, ១៩៥៥, ៩៥ទំព័រ។

៦-ស្នេហារក្សាចិត្ត, ១៩៥៥, ១៤៨ទំព័រ។

៧. ស្នេហានិងករណីយកិច្ច, ១៩៥៥, ១៥០ទំព័រ។

៨-ពន្លឺពេជ្រ, ១៩៥៥, ៨៧ទំព័រ។

៩-ផ្ការុះដោយខ្យល់, ១៩៥៥, ៥៧ ទំព័រ។

១០-នារីចិត្រពីរ, ១៩៥៥, ៦៩ទំព័រ។

---

[7] ពត៌មាននេះបានពីលោកវ៉ាន់ឌីកាអុននិងបណ្ឌិតសភាចារ្យ រស់ចន្ត្រាបុត្រៗក៏បានបង្កើតសារពត៌មានមួយដែរនាឆ្នាំ១៩៦៧ឈ្មោះ កាសែត "មហាជន"។សូមអរគុណលោកទាំងពីរ។

១១-ទឹកភ្នែកនារី, ១៩៥៥, ២៥៦ទំព័រ។

១២- ឈាមហូរលើកំពូលភ្នំ, ១៩៥៥, ៥៣ទំព័រ។

១៣-នារីសម័យ, ១៩៥៦, ១៨៧ទំព័រ។

១៤- នារីល្អ...ពន្លកភ្លើងចិត្ត, ១៩៥៦, ២៦៨ទំព័រ។

១៥-កម្លាំងចិត្ត, ១៩៥៦, ៨៦ទំព័រ។

១៦-ឈឺចិត្តណាស់បង, ១៩៥៦, ៧៩ទំព័រ។

១៧-បក្សផ្កាយព្រឹក, ១៩៥៧, ៩២ ទំព័រ។

១៨-កញ្ញាកំសត់, បាត់ដំបង, បណ្ណាគារអ៊ឹង-ហ៊ុន, ១៩៥៨,

៨៦ទំព័រ។

១៩-ផ្ការុះមាត់ស្ទឹង, ១៩៥៩, ១២២ទំព័រ។

២០-ភរិយាចំណាប់, ១៩៦០, ២១៥ទំព័រ

២១-ទឹកហូរមិនចេះហត់, ភ្នំពេញ, ១៩៦០ (បោះទី២នាឆ្នាំ

២០០៣), ៩២ទំព័រ។

២២-ម៉ានី ស្រីកំសត់, ១៩៦២, ២៥៥ទំព័រ។

២៣-បុត្រចំណាន, ១៩៦២, ៩៨ទំព័រ។

២៤-បុប្ផាជើងភ្នំ, ១៩៦៣, ១៧៣ទំព័រ។

២៥-ក្រឡុះចិត្តក្រឡាប់ប្រាណ, ១៩៦៣, ១០០ទំព័រ។

២៦-ឯណាកូនស្រីខ្ញុំ, ១៩៦៦, ១៩៤ទំព័រ។

២៧-រឿងបាតដៃស្ថាបនា, ១៩៦៦, ៩១ទំព័រ។

២៨-រឿងបញ្ចពណ៌ទេវី ឬស្នេហាអមតៈ, ១៩៦៧, ៦៣ទំព័រ។

សៀវភៅសិក្សា៖

១-វាក្យស័ព្ទខ្មែរ-បារាំង-យួន, ភ្នំពេញ, បណ្ណាគារជុកឈឿន (លេខ៨៨វិថីឧកញ៉ាផ្ទង់), គ្មានកាលបរិច្ឆេទ។

២-កុមារដ្ឋានខ្មែរ-យួន, ភ្នំពេញ,បណ្ណាគារជុកឈឿន(លេខ៨៨វិថីឧកញ៉ាផ្ទង់), គ្មានកាលបរិច្ឆេទ។

៣-សង្គមវិជ្ជា, ភ្នំពេញ,បណ្ណាគារជុកឈឿន(លេខ៨៨វិថីឧកញ៉ាផ្ទង់), គ្មានកាលបរិច្ឆេទ។

៤-តែងសេចក្ដីថ្នាក់ទី៨, ភ្នំពេញ,បណ្ណាគារជុកឈឿន(លេខ៨៨វិថីឧកញ៉ាផ្ទង់), គ្មានកាលបរិច្ឆេទ។[8]

៥. កម្ពុជាតស៊ូដើម្បីឯករាជ្យ, សន្តិភាពអព្យាក្រឹតនិងប្រជាធិប

---

[8] KHUON Sokhamphu, *Le roman khmer contemporain*, 1973, 56 p. C'est un papier pour la communication au XXIXe Congrès international des Orientalistes à Paris, 1973. Il est partiellement publié dans *Actes du XXIXe Congrès international des Orientalistes*. Section organisée par Pierre-Bernard Lafont, Asie du Sud-Est continentale, vol. 3, Paris, L'Asiathèque, 1976, pp.204-208 ; cf. *Catalogue des auteurs et des livres publiés au Cambodge*, Phnom-Penh, Bibliothèque de l'Association des Ecrivains khmers, 1966, 24 p. ; ម៉ុញ-សារី, សទ្ទានុក្រមអក្សរសិល្ប៍ខ្មែរ, ភ្នំពេញ, ៣៣៦ទំព័រ, ឃីងហុកឌី, *អក្សរសិល្ប៍ខ្មែរសតវត្សទី២០-កវីនិពន្ធនិងកម្រងអត្ថបទ (Littérature cambodgienne du XXe siècle. Ecrivains et textes)*, ភ្នំពេញ, បណ្ណាគារអង្គរ, ២០០៧, ៦១២ទំព័រ។

តេយ្យ ក្រោមការដឹកនាំដ៏ក្ដីក្ដីស្វាងព្រះនរោត្តសីហនុ, ភ្នំពេញ, បណ្ណាគារ តិច-ហុង, ១៩៥៦, ៥៦ ទំព័រ។

៦. បញ្ហាសន្តិភាព, ភ្នំពេញ, បណ្ណាគារ វប្បធម៌ថ្មី, ១៩៥៧, ១៥ទំព័រ។

៧. វិជ្ជានិពន្ធខ្មែរ, ភ្នំពេញ, បណ្ណាគារ តិច-ហុង, ១៩៥៩។[9]

៨. ច្បាប់បណ្ដាំបិតា (ចម្លងចេញពីសាស្ត្រាស្លឹករឹត), ភ្នំពេញ, ពុទ្ធសាសនបណ្ឌិត្យ, ១៩៦៥ (បោះពុម្ពឡើងវិញ ឆ្នាំ២០០១), ២៣ ទំព័រ។

៩. ទស្សនវិជ្ជា អត្ថិភាពនិយម **L'existentialisme**, ភ្នំពេញ, ១៩៧៣, ១០៤ទំព័រ។

១០. ការពន្យល់និងទិទៀនអក្សរសាស្ត្រ (នៅថ្នាក់ទី៣ទំនើប), កំពង់ចាម, បណ្ណាគារ វង់រស្មី, គ្មានកាលបរិច្ឆេទ, ១៧៤ទំព័រ។

១១. វេយ្យករណ៍ទំនើបនិងវិធីសម្ពន្ធ (ផ្សាយនៅលើក្របសៀវភៅខាងលើ៖ ការពន្យល់និងទិទៀនអក្សរសាស្ត្រ)។

ប្រលោមលោកទាំង២៨នេះ លោកបានសរសេរក្នុងប្រធានបទផ្សេងៗគឺមានប្រលោមលោកបែបមនោសញ្ចេតនាដូចជារឿង "ដើងមេឃថ្មី", រឿង"ផ្ការុះដោយខ្យល់", រឿង"ឈឺចិត្តណាស់បង", រឿង"កញ្ញាកំសត់" រឿង"ក្រឡះក្រឡាប់ប្រាណ", រឿង"បញ្ចពណ៌

---

[9] *Vernacular Monographs Cambodia, Southeast Asia Catalog,* Card files of Cornell University Libraries.

ទេវីឬស្នេហាអមត:″ ជាដើម។ ប្រលោមលោកបែប រឿងផ្សេងព្រេង ដូចជារឿង″ឈាមលើកំពូលភ្នំ″, រឿង″បក្សផ្កាយព្រឹក″ជាដើម។ ប្រលោមលោកបែកអាថ៌កំបាំង ដូចជារឿង″ស្រមោលមហាចោរ″, រឿង″ពន្ទីពេជ″។ ប្រលោមលោកបែប ស៊ើបអង្កេត ដូចជារឿង″ស្នូរកាំភ្លើងនៅក្រោយពេលភ្លៀងធ្លាក់″ ប្រលោមលោកទាក់ទងនឹងសង្គមដូចជា″នារីរាត្រី″, រឿង″ឯណាកូនស្រីខ្ញុំ″។ ប្រលោមលោកទាក់ទងនឹងចិត្តសាស្ត្រនិងទស្សនវិជ្ជាដូចជារឿង "ស្នេហាចិត្ត១″, រឿង″ស្នេហារក្សាចិត្ត″, រឿង″ស្នេហានិងករណីយកិច្ច″, រឿង″នារីចិត្តពីរ″, រឿងទឹកភ្នែកនារី″, រឿង″នារីសម័យ″។ល។ ទាំងនេះបានសេចក្តីថា ប្រលោមលោកបែបមនោសញ្ចេតនា មានច្រើនជាងប្រភេទប្រលោមលោកដទៃទៀត។

លោកគីមសែតក៏បានសរសេរសៀវភៅសិក្សាស្រាវជ្រាវ និងសៀវភៅសម្រាប់សិស្សសិក្សា១១ថែមទៀតគឺ ជាសៀវភៅទាក់ទងនឹងនយោបាយដូចជា″កម្ពុជាតស៊ូដើម្បីឯករាជ្យ″, "បញ្ហាសន្តិភាព″ សៀវភៅទាក់ទងនឹង សង្គមនិងទស្សនវិជ្ជា ដូចជាសៀវភៅ "សង្គមវិជ្ជា″, សៀវភៅ "ទស្សនវិជ្ជា អត្ថិភាពនិយម **L'existentialisme**″។ លោកក៏បានសរសេរសៀវភៅសិក្សាពីភាសា, អក្សរសាស្ត្រ ដូចជា″ការពន្យល់និងទិទៀនអក្សរសាស្ត្រ″, ច្បាប់សីលធម៌ដូចជា″ច្បាប់បណ្តាំបិតា″ និង វិធីតែងសេចក្តី និងនិពន្ធផ្សេងៗទៀត។ល។

ចំពោះស្នាដៃលោកសំខាន់ក្នុងទស្សនវិជ្ជា គឺ "ទស្សនវិជ្ជាអត្ថិភាពនិយម L’existentialisme" ដោយលោកមានបំណងចង់បង្ហាញទស្សនវិទូ ល្បីៗនៅប្រទេសអ៊ឺរ៉ុបពីទ្រឹស្តីអត្ថភាពនិយមនិងការវិត្តន៍នៃទ្រឹស្តីនេះដូចជាៈ

-Kierkegaard,

-Nietzche,

-Husserl,

-Jaspers,

-Marcel,

-Sartre

-Heidegger ជាដើមៗ

នៅទសវត្សរ៍រវាង១៩៦០ និង ១៩៧០ ចរន្តទ្រឹស្តីអត្ថិភាពនិយម L’existentialisme សាយភាយពាសពេញ នៅទ្វីបអ៊ឺរ៉ុបដូចជានៅប្រទេស ដានឺម៉ាក, អាល្លឺម៉ាញ, បារាំង, ស្វីស, ហុងគ្រី ជាដើម ហើយនៅប្រទេសបារាំងគឺមានទស្សនវិទូដ៏ល្បីល្បាញម្នាក់ដែលគេស្គាល់ជាងគេនៅលើពិភពលោកគឺលោកសាស្ត្រាចារ្យហ្សង់ប៉ូលសាត្រ (Jean-Paul SARTRE) នេះឯងដែលបានបង្ហាញពីទ្រឹស្តីអត្ថភាពនិយមៗ លោកជាអ្នកប្រឆាំងយ៉ាងខ្លាំងក្លានឹង

សង្គ្រាមនៅប្រទេសវៀតណាមដែលបង្កបង្កើតឡើងដោយសហរដ្ឋអាមេរិក។ល។

ដោយចេតនាចង់គោរពដល់វិញ្ញាណក្ខន្ធលោកគីមសែតដែលជាបុព្វការីផ្នែកអក្សរសាស្ត្រខ្មែរមួយរូបដែលបានបូជាកាយនិងចិត្តបម្រើវប្បធម៌អរិយធម៌ខ្មែរ។ ហេតុនេះហើយបានជាខំស្រាវជ្រាវរាវរកស្នាដៃលោកនិងជីវប្រវត្តិលោកដើម្បីនឹងផ្សាយឲ្យជនានុជនជំនាន់ក្រោយបានដឹងកុំបំភ្លេចរូបនិងកេរ្តិ៍លោកលោកទៅថ្ងៃក្រោយ។

សូមឲ្យវប្បធម៌អរិយធម៌នៅគង់វង់ជាអមតៈតរៀងទៅ!

# ឧបសម្ព័ន្ធ

នេះជាសារអេឡិចត្រូនិច ចៅប្រសារលោកគីមសែតជាជនជាតិបារាំង ឈ្មោះ **Cyril Royer** សាកសួរខ្ញុំពីជីវប្រវត្តិជីតាភរិយាខ្លួនជាច្រើនដងជាយូរមកហើយដូចមានសារខាងក្រោមនេះ៖

**Cyril Royer**
**<cyril_royer@hotmail.com>**

23 mai 2016(Il y a 11 jours)

À moi, hocdykhing

Bonjour,

Excusez-moi de vous déranger à nouveau, je vous avais contacté il y a environ 6 ans au sujet de l'écrivain KIM Set, qui pourrait être le grand-père de ma femme. Si ma belle-mère m'a dit "qu'il écrivait beaucoup" quand elle était petite, elle ne sait pas quel était alors le métier de son père. A la fin  des années 60 il a changé de prénom et de métier, cela pourrait expliquer l'arrêt des publications de romans de l'écrivain.

Vous m'aviez mentionné que l'écrivain KIM Set était professeur de khmer dans un lycée privé de la capitale, de quel lycée s'agissait-il ?

Je me suis demandé si au cours de vos recherches vous avez peut-être trouvé une photo de l'écrivain ou si vous connaissez peut-être encore une personne qui le connaissait personnellement (afin de le confondre par l'identité de sa femme) ??

Par avance merci pour votre attention.

J'ai lu plusieurs de vos articles ces dernières années sur le site de l'AEFEK, vous faites un très beau travail.

Encore merci.

Bonne journée.

*នេះជាសារ១ទៀតរបស់ចៅប្រសារបារាំង៖*

**Cyril Royer** 26 mai

Rebonjour,

Je vous dérange une dernière fois simplement pour partager une réflexion avec vous. Comme les pièces d'un puzzle qui prends lentement forme.

Si l'écrivain KIM Set a été enseignant au lycée Kampucheaboth, alors il s'identifie probablement à KIM Seth, "ami proche" de Ieng Sary (cité sur sa fiche biographique du dccam) qui a été également enseignant là bas dans les années 50.

Mon beau père m'avait dit que son beau-père "avait travaillé pour le roi et qu'il lui avait demandé de le suivre à Pékin mais il avait préféré rester à Phnom Penh". J'avais toujours trouvé ça étrange et je n'y croyais pas trop.
Ce n'est peut être pas le roi mais ça pourrait être HOU Yuon par exemple qui le lui avait demandé. Dans ce cas cela s'expliquerais puisqu'ils devaient se connaitre aussi.

Si KIM Set a connu, fréquenté (voir été) le milieu communiste/khmer rouge, cela expliquerais également pourquoi sa fille et beau fils ne parlent absolument jamais de lui.

En tout cas merci encore pour votre aide et vos recherches en général.
Cordialement.




កញ្ញាកំសត់, បាត់ដំបង, បណ្ណាគារអ៊ឹង-ហ៊ុន, ១៩៥៨។




ទឹកហូរមិនចេះហត់, ភ្នំពេញ, ១៩៦០ (បោះទី២២០០៣)។




គីមសែត, ទស្សនវិជ្ជា អត្ថិភាពនិយម, L'EXISTENTIALISME,

ភ្នំពេញ, ១៩៧៣, ១០៨ទំព័រ។


០៨៦.១៨គ

គីម_សែត

ទស្សនវិជ្ជា

អត្ថិភាពនិយម

LEXISTENTIALISME

| |
|---|
| អត្ថិភាពនិយម ជាទស្សនវិជ្ជាសម័យថ្មី កំពុងជ្រួតជ្រាបក្នុងលោក, កំពុងទាក់ទាញ ប្រជាពលលោក ពិសេសគឺយុវជន |

ទំព័រទី១




ការពន្យល់និងទិទៀនអក្សរសាស្ត្រ (នៅថ្នាក់ទី៣ទំនើប), កំពង់ចាម, បណ្ណាគារ វង់រស្មី, គ្មានកាលបរិច្ឆេទ, ១៧៤ទំព័រ។